# ៦. ការរីកចំរើន និង ផលប៉ះពាល់នៃកំណែទំរង់អប់រំទូទាំងវិស័យ

## ៦.១ ផលប៉ះពាល់របស់ភាពក្រីក្រក្នុងកំណែទំរង់វិស័យអប់រំ

ក្រសួងអប់រំ យុវជន និងកីឡា នៅតែបន្តអោយមានការយកចិត្តទុកដាក់លើភាពក្រីក្រ ក្នុងការវាយតំលៃការបំពេញការងារវិស័យអប់រំ ព្រមទាំងមានការកំណត់ចំណុចដៅយុទ្ធសាស្ត្រនៅក្នុងកម្មវិធី និងអន្តរាគមន៏នីមួយៗ សំដៅជួយជនក្រីក្រ (ឧទាហរណ៏ ការផ្តល់អាហារូបករណ៏ និងសម្ភាររូបវ័ន្ត)។ យោងតាមសន្ទស្សន៏នៃភាពក្រីក្រ ដែលរៀបចំដោយកម្មវិធីស្បៀងអាហារពិភពលោក (WFP) ឃុំទាំងអស់ត្រូវបានចែកជា៥ស្រទាប់( ស្រទាប់១=ក្រីក្របំផុត ស្រទាប់៥=មានបំផុត)។

តាមការសង្កេតលើការចូលរៀននៅបឋមសិក្សា តាំងពីឆ្នាំ២០០១-២០០២មក កំណើនសិស្សមានភាពឃឹតគួរអោយកត់សំគាល់។ ក្នុងរយៈពេល២ឆ្នាំចុងក្រោយ នៅក្នុងឃុំស្រទាប់ទី៥មានកំណើនអវិជ្ជមាន ចំណែកឃុំក្នុងស្រទាប់ទី១ និងទី២ (ឃុំស្រទាប់ក្រោមបំផុត ៤០%) មានកំណើនវិជ្ជមាន។ កំណើនទាំងនេះបានធ្វើអោយការផ្តល់សេវាអប់រំនៅបឋមសិក្សាកាន់តែមានសមភាពនៅគ្រប់ស្រទាប់ក្រីក្រទាំងអស់។ ឧទាហរណ៏ ក្នុងរយៈពេល៤ឆ្នាំកន្លង ស្រទាប់ទី១ បានកើនពី ១៥.១% ទៅ ១៧.៨% បើធៀបទៅនឹងការថយចុះពី ២២.២% មក២០% នៅក្នុងស្រទាប់ទី៥។ វាបានបង្ហាញពីការកាត់បន្ថយគំលាតរវាងការអប់រំ និង ភាពក្រីក្រពី ៧.១ មកត្រឹម ២.២។ ម្យ៉ាងទៀត យុទ្ធសាស្ត្របើកទូលាយរបស់ក្រសួងអប់រំ យុវជន និងកីឡា កំពុងបន្តមានផលប៉ះពាល់គួរអោយកត់សំគាល់ លើការកែលំអសមធម៌ នៃការចូលរៀនទៅតាមក្រុមសង្គម-សេដ្ឋកិច្ចដ៏ទូលាយ ជាពិសេសការលុបបំបាត់ការបង់វិភាគទានដើមឆ្នាំសិក្សា។

*រូបភាពទី ៧ : កំណើននៃការចូលរៀននៅបឋមសិក្សាជារួម តាមស្រទាប់ភាពក្រីក្រ*



អត្រាឆ្លងភូមិសិក្សាទៅមធ្យមសិក្សាបឋមភូមិ មានភាពខុសគ្នារវាងឆ្នាំ២០០២-០៣ និងឆ្នាំ២០០៣-០៤ ដោយមាន ៩៥% ជាកូនមកពីគ្រួសារក្នុងស្រទាប់ទី៥ ធៀបទៅនិង ៦៤% ជាកូនមកពីគ្រួសារក្នុងស្រទាប់ទី១ ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងអំឡុងពេល៣ឆ្នាំកន្លងមកនេះ កំណើនសិស្សមកពីគ្រួសារក្នុងស្រទាប់ទី១ ចូលរៀនថ្មីនៅមធ្យមសិក្សាបឋមភូមិមាន៣២% នៅតែមានលំនឹងដដែល បើធៀបទៅនិងកំណើនយឺតៗរបស់សិស្ស មកពីគ្រួសារក្នុងស្រទាប់ទី៥ដែលមាន៤.៣% ។ ដោយឡែក ក្នុងឆ្នាំសិក្សា២០០៣-២០០៤នេះ កំណើនសិស្សស្រីចូលរៀនថ្មី នៅតែកើនឡើងយ៉ាងខ្លាំងដដែល ដោយមានចំនួនបន្ថែម ១,០០០នាក់ ទៀតបានចូលរៀននៅថ្នាក់ទី៧ ។

ជារួម កំណើនសិស្សចូលរៀនខ្ពស់បំផុត ២៧% ជាសិស្សមកពីគ្រួសារក្នុងស្រទាប់ទី១ បើធៀបទៅនឹងសិស្សមកពីគ្រួសារក្នុងស្រទាប់ទី៥ដែលមានតែ ៩%ប៉ុណ្ណោះ ។ ក្នុងឆ្នាំសិក្សា២០០៣-០៤នេះ ចំនួនសិស្សបានកើនឡើង ៧,០០០នាក់ ដែលជាកូនមកពីគ្រួសារនៃស្រទាប់ទាំងពីរ ។ ជារួម គោលនយោបាយហិរញ្ញប្បទានអប់រំ សំរាប់អ្នកក្រីក្រមានផលប៉ះពាល់ដល់ការចូលរៀនថ្មីនៅថ្នាក់ទី៧ ស្របទៅនឹងយុទ្ធសាស្ត្រពង្រីកការអប់រំមធ្យមសិក្សាបឋមភូមិ សំរាប់សិស្សក្រីក្រ ។ ចាប់តាំងពីឆ្នាំ ២០០០មក សាលាមធ្យមសិក្សាបឋមភូមិចំនួន១១៧ បានបង្កើត ហើយ៧៣%នៃសាលាទាំងនេះ ស្ថិតនៅក្នុងឃុំនៃស្រទាប់ទី១ និងទី២ ។

*រូបភាពទី ៨ : កំណើនសិស្សថ្មីថ្នាក់ទី ៧*




| | Q1 (Poorest) Female | Q1 Male | Q1 Total | Q2 Female | Q2 Male | Q2 Total | Q3 Female | Q3 Male | Q3 Total | Q4 Female | Q4 Male | Q4 Total | Q5 (Richest) Female | Q5 Male | Q5 Total |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 2001 - % | 50.2% | 23.1% | 32.1% | 27.7% | 17.1% | 21.1% | 26.5% | 15.0% | 19.5% | 24.0% | 13.6% | 17.7% | 15.0% | 10.4% | 12.3% |
| 2002 - % | 38.3% | 26.7% | 31.0% | 29.5% | 15.2% | 20.9% | 26.1% | 16.0% | 20.1% | 23.4% | 13.1% | 17.4% | 11.2% | 6.0% | 8.2% |
| 2003 - % | 46.4% | 23.5% | 32.6% | 12.5% | 7.7% | 9.8% | 18.0% | 10.2% | 13.6% | 15.3% | 9.9% | 12.3% | 7.6% | 1.6% | 4.3% |
| 2001 - Vol | 1195 | 1120 | 2315 | 2226 | 2268 | 4494 | 2288 | 2042 | 4330 | 2818 | 2474 | 5292 | 2948 | 2836 | 5784 |
| 2002 - Vol | 1368 | 1589 | 2957 | 3026 | 2356 | 5382 | 2848 | 2505 | 5353 | 3398 | 2707 | 6105 | 2539 | 1809 | 4348 |
| 2003 - Vol | 2296 | 1777 | 4073 | 1656 | 1382 | 3038 | 2476 | 1852 | 4328 | 2749 | 2321 | 5070 | 1907 | 523 | 2430 |

**Poverty Quintile/Gender**

ថ្វីត្បិតតែមានការកែលំអទាំងនេះក៏ដោយ វិសមភាពនៃការចូលរៀននៅថ្នាក់ទី៧-៩នៅតែមានសភាពធ្ងន់ធ្ងរ ។ ក្នុងរយៈពេល៤ឆ្នាំចុងក្រោយនេះ ការចូលរៀនរបស់កូនមកពីគ្រួសារនៃឃុំក្រីក្របំផុត ២០% បានកើនពី ៥.៤% ដល់ ៧.៧% ។ ចំណែក ឯការចូលរៀនរបស់កូនមកពីគ្រួសារនៃឃុំមានបំផុតបានធ្លាក់ចុះ ៥.១% ក្នុងរយៈពេលដូចគ្នា ។ ការចូលរៀនថ្នាក់ទី៧-៩ របស់កូនមកពីគ្រួសារនៃឃុំមានបំផុតនៅតែមានចំនួនច្រើនដដែល ។

តាំងពីឆ្នាំ២០០០-០១មក វិសមភាពនៃការចូលរៀននៅថ្នាក់ទី១០-១២ កាន់តែមានសភាពធ្ងន់ធ្ងរថែមទៀត។ សិស្សក្នុងស្រទាប់មានបំផុតបានចូលរៀនច្រើនជាង ៥០% ធៀបនឹងសិស្សក្នុងស្រទាប់ក្រីក្របំផុតដែលមានតែ ២.២% ប៉ុណ្ណោះ ក្នុងឆ្នាំសិក្សា២០០៣-០៤។ នៅមធ្យមសិក្សាទុតិយភូមិ សិស្សក្នុងស្រទាប់ក្រីក្រទី២ និងទី៣ ក៏មានចំនួនតិចតួចប្រហែល ១៣%-១៤% ប៉ុណ្ណោះ។ ក្រសួងអប់រំ យុវជន និងកីឡាត្រូវមានវិធានការបន្ថែម ដើម្បីជំរុញអោយមានកំណើនសិស្សកាន់តែច្រើន និងធានាអោយមានសិស្សមកពីគ្រួសារគ្រប់ស្រទាប់ ជាពិសេសស្រទាប់ទី១។

បទពិសោធដែលទទួលបានគឺ នៅក្នុងមធ្យមសិក្សាបឋមភូមិ ការផ្តល់ថវិកាដំណើរការសាលារៀន ដើម្បីលុបបំបាត់ការបង់វិភាគទានរបស់មាតាបិតាសិស្សនោះ មិនទាន់ធ្វើអោយមានសមធម៌ក្នុងការចូលរៀននៅឡើយទេ។ ម្យ៉ាងវិញទៀតក្នុងរយៈពេល៤ឆ្នាំចុងក្រោយនេះ សាលារៀនដែលបានសាងសង់រួច ស្ថិតនៅក្នុងឃុំស្រទាប់ក្រីក្របំផុត ៤០%។ ឃុំក្នុងស្រទាប់ទី១ ចំនួន៧១% ពុំមានសាលាមធ្យមសិក្សាបឋមភូមិទេ ធៀបទៅនឹងឃុំឯទៀតដែលមានប្រហែល ៥០%។ នៅទូទាំងប្រទេស ឃុំជាង ៩០០ ពុំមានសាលាមធ្យមសិក្សាបឋមភូមិទេ។ កត្តាផ្សេងទៀតនោះគឺ វិភាគទាន ដើមឆ្នាំសិក្សា នៅតែជាចំណាយក្រៅផ្លូវការរបស់មាតាបិតាសិស្ស។ ឆ្លើយតបទៅនឹងបញ្ហានេះ ក្រសួងអប់រំ យុវជន និងកីឡាកំពុងពន្លឿនការសាងសង់សាលាមធ្យមសិក្សានៅក្នុងឃុំក្រីក្របំផុត និងអនុវត្តគោលនយោបាយលុបបំបាត់ចំណាយក្រៅផ្លូវការ និងកំពុងពង្រីកកម្មវិធីផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រថ្នាក់ទី៧-៩ នៅទូទាំងប្រទេស។

ការវិភាគលើអាំងឌីកាទ័រស្តីពីប្រសិទ្ធភាពនានាបង្ហាញថា វិសមភាពនៅក្នុងការបែងចែកគ្រូ និង សម្ភាររូបវ័ន្តនៅមាននៅឡើយ។ ឧទាហរណ៏: ផលធៀបសិស្ស-គ្រូ នៅបឋមសិក្សាក្នុងឆ្នាំសិក្សា២០០៣-០៤ ក្នុងស្រទាប់ទី១ មាន ៧៨ ធៀបទៅនឹងស្រទាប់ទី៥ ដែលមានតែ ៤៤ ប៉ុណ្ណោះ និងធៀបទៅទូទាំងប្រទេសមាន ៥៥។ មានការប្រើប្រាស់សម្ភាររូបវ័ន្ត ២វេន នៅគ្រប់ស្រទាប់ទាំងអស់។ នៅស្រទាប់ទី១ មានផលធៀបសិស្ស-បន្ទប់រៀន ៧៥ ធៀបនឹងស្រទាប់ទី១ ដែលមានផលធៀបសិស្ស-បន្ទប់រៀន ៦៩។ ទោះជាយ៉ាងណាក៏ដោយ ការចូលរៀននៅបឋមសិក្សាក្នុងស្រទាប់៥ មានត្រឹមតែ ២១% ប៉ុណ្ណោះ ខ្ពស់ជាងស្រទាប់ទី ១ ប៉ុន្តែមានបន្ទប់រៀនច្រើនជាង ៣១%។

នៅក្នុងស្រទាប់ទី១ អត្រាបោះបង់ការសិក្សានៅបឋមសិក្សា របស់សិស្សក្នុងស្រទាប់ទី១ខ្ពស់ជាងស្រទាប់ទី៥ គឺ១៦% ក្នុងឆ្នាំ២០០២-០៣ និង ៩.៥% ក្នុងឆ្នាំ២០០៣-០៤។ កត្តាចំបងនៃការខុសគ្នានេះគឺ នៅក្នុងឃុំនានានៃស្រទាប់ក្រីក្របំផុត ចំនួនសាលារៀនមានមិនគ្រប់កំរិតថ្នាក់មានចំនួនច្រើន។ សាលាបឋមសិក្សាក្នុងឃុំក្រីក្របំផុតចំនួន ៥០% (សរុប ៥៩២សាលា) ពុំមានគ្រប់កំរិតថ្នាក់ទេ ធៀបនឹងឃុំស្រទាប់ទី៥ ដែលមានតែ ២៧% ប៉ុណ្ណោះ (សរុប ២៦៨)។

ថ្វីត្បិតតែមានភាពខុសប្លែកគ្នាក៏ដោយ នៅបឋមសិក្សាក្នុងឃុំក្រីក្របំផុត ចំណុះសិស្សជាមធ្យមគឺ ៤៨នាក់ ខ្ពស់ជាងឃុំមានបំផុតដែលមានតែ ៤៣នាក់ប៉ុណ្ណោះ។ ម្យ៉ាងទៀត ទោះបីមានបញ្ហាចំណុះសិស្ស និងកង្វះខាតបុគ្គលិកក៏ដោយ សាលាបឋមសិក្សាក្នុងឃុំក្រីក្របំផុតបានបង្ហាញអាំងឌីកាទ័រនៃគុណភាព និងប្រសិទ្ធភាពដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងឃុំមានបំផុត។ សាលារៀនក្នុងឃុំក្រីក្រទាំងនេះ កំពុងខិតខំប្រឹងប្រែងយ៉ាងខ្លាំង ក្នុងការប្រើប្រាស់ធនធានដែលមានកំរិត ដូចជាបង្កើនការបង្រៀន២វេន និងថ្នាក់គួប និងផ្តល់ប្រាក់ឧបត្ថម្ភសំរាប់គ្រូបង្រៀនទៀតផង។

## ៦.២ ការវិភាគផលប៉ះពាល់ និងការរីកចំរើនកំណែទំរង់អប់រំ តាមផ្នែកយេនឌ័រ និងជនជាតិភាគតិច

### ៦.២.១ ការរីកចំរើន និងផលប៉ះពាល់លើយេនឌ័រ

កំណែទំរង់នានាកំពុងបន្តធ្វើអោយមានផលប៉ះពាល់ជាវិជ្ជមានដល់ការចូលរៀនរបស់កុមារីនៅបឋមសិក្សា និងមធ្យមសិក្សា។ ឆ្នាំសិក្សា២០០៣-០៤ ចំនួនសិស្សស្រីនៅក្នុងបឋមសិក្សាបានកើនចំនួន៧,០០០នាក់ ធៀបនឹងការថយចុះនៃការចូលរៀនរបស់សិស្សប្រុស។ កំណើននេះ បណ្តាលមកពីការកើនឡើងរបស់សិស្សស្រីនៅតំបន់ជនបទ និងតំបន់ដាច់ស្រយាល (កំណើនប្រហែល ១២,០០០នាក់ ច្រើនជាងកំណើនសរុប ដោយសារការថយចុះនៃការចូលរៀនរបស់សិស្សស្រនៅតំបន់ទីប្រជុំជន )។ ចាប់តាំងពីឆ្នាំ២០០០មក សិស្សស្រីនៅបឋមសិក្សា បានកើនឡើងពី ១.១១ លាននាក់ ដល់ ១.២៩លាននាក់ (កំណើនសិស្សស្រី ១៦% ប្រុស ១២%)។ កំណើននេះបង្ហាញថា ការលុបបំបាត់ការយកវិភាគទានសិស្សដើមឆ្នាំសិក្សា ធ្វើអោយមានផលប៉ះពាល់ជាវិជ្ជមានដល់ការចូលរៀនរបស់កុមារីនៅបឋមសិក្សា។

រយ:ពេល៤ឆ្នាំកន្លងទៅនេះ អត្រាកំណើននៃសិស្សស្រីនៅក្នុងមធ្យមសិក្សាបឋមភូមិមានប្រហែល ៧%-៩% ខ្ពស់ជាងសិស្សប្រុស។ ចាប់តាំងពីឆ្នាំ២០០០-០១ មកចំនួនសិស្សស្រីនៅមធ្យមសិក្សាបឋមភូមិបានកើនឡើង ៨៤% ជិតប្រហែល ២០០,០០០នាក់ ក្នុងឆ្នាំ២០០៣-០៤។ ភាគរយសិស្សស្រីបានកើនពី៣៧% ដល់៤២% នៅក្នុងរយ:ពេលដូចគ្នា។ អត្រាឆ្លងភូមិសិក្សាទៅមធ្យមសិក្សារបស់សិស្សស្រីបានកើនពីប្រហែល ៧១% ក្នុងឆ្នាំ១៩៩៩-០០និង ២០០០-០១ ដល់ ៨០% ក្នុងឆ្នាំ២០០២-០៣ និងឆ្នាំ២០០៣-០៤ ។ ជាឧទាហរណ៍: ក្នុងឆ្នាំ២០០៣-០៤ មានសិស្សស្រីប្រហែល ៨៨,០០០នាក់ បានចូលរៀនថ្នាក់ទី៧ ធៀបនឹងឆ្នាំ ២០០០-០១ ដែលមានសិស្សស្រីចូលរៀនតែ ៥១,០០០នាក់ប៉ុណ្ណោះ (កើន ៧៣%)។

*រូបភាពទី ៩ : គំលាតយេនឌ័រនៅគ្រប់កំរិតសិក្សា ឆ្នាំ២០០០-០១ ដល់ឆ្នាំ២០០២-០៣*



កំណើនសិស្សចូលរៀននៅមធ្យមសិក្សាទុតិយភូមិ និងកំរិតក្រោយមធ្យមសិក្សាមានចំនួនតិចតួច។ ក្នុងឆ្នាំសិក្សា ២០០៣-០៤ មានសិស្សចំនួន ២៥,០០០នាក់ ប៉ុណ្ណោះបានចូលរៀននៅថ្នាក់ទី១០ (៣៧% នៃចំនួនសរុប)។ ទោះបីយ៉ាងណាក៏ដោយចំនួននេះបានកើន២២០% ធៀបនឹងចំនួន ៧,៦០០នាក់ ដែលបានចូលរៀនក្នុងឆ្នាំ២០០០-០១។ ការចូលរៀនសិស្សស្រីនៅថ្នាក់ទី១០-១២បានកើនឡើងជាបន្តបន្ទាប់ពី៣២%ក្នុងឆ្នាំ២០០០-០១ ដល់៣៦%ក្នុងឆ្នាំ២០០៣-០៤។ ការចូលរៀនសិស្សស្រីនៅមធ្យមសិក្សាទុតិយភូមិមានចំនួនតិច ធ្វើអោយការចូលរៀននៅកំរិតឧត្តមសិក្សា និង TVET ក៏មានចំនួនតិចដែរ ដែលមានប្រហែល ២០-២៥% ប៉ុណ្ណោះ។

*តារាងទី៨: គំលាតយេនឌ័រនៃអត្រាពិតនៃការសិក្សាទូទាំងប្រទេស- គ្រប់កំរិតថ្នាក់*

| | បឋមសិក្សា | | | មធ្យមសិក្សាបឋមភូមិ | | | មធ្យមសិក្សាទុតិយភូមិ | | |
|---|---|---|---|---|---|---|---|---|---|
| ឆ្នាំសិក្សា | ស្រី | ប្រុស | គំលាតយេនឌ័រ | ស្រី | ប្រុស | គំលាតយេនឌ័រ | ស្រី | ប្រុស | គំលាតយេនឌ័រ |
| ២០០០ | ៨០.៧% | ៨៦.៩% | ៦.២ | ១៣.៧% | ១៩.៥% | ៥.៨ | ៥.៤% | ១០.០% | ៤.៥ |
| ២០០១ | ៨៤.២% | ៨៩.៨% | ៥.៧ | ១៦.៤% | ២១.៤% | ៥.១ | ៥.៤% | ៩.៣% | ៣.៨ |
| ២០០២ | ៨៨.៩% | ៩៧.១% | ៨.១ | ១៧.៩% | ២២.០% | ៤.១ | ៥.៦% | ៨.៦% | ៣.១ |
| ២០០៣ | ៨៨.៦% | ៩១.៥% | ២.៨ | ១៩.៨% | ២២.៧% | ២.៨ | ៦.៦% | ៩.៦% | ៣.០ |

ទោះបីជាមានការកែលំអយ៉ាងណាក៏ដោយ ក្រសួងអប់រំ យុវជន និងកីឡាបានទទួលស្គាល់ថា ចាំបាច់ត្រូវមានយុទ្ធសាស្ត្រនានាបន្ថែមទៀត ដើម្បីបង្កើនការចូលរៀនរបស់នារីភេទនៅគ្រប់កំរិតនៃការអប់រំ។ នៅដើមឆ្នាំ២០០៣ ក្រសួងបានរៀបចំផែនការសកម្មភាពដំបូង តាមរយៈក្រុមការងារបញ្ជ្រាបយេនឌ័រ។ ការលុបបំបាត់ការបង់វិភាគទានដើមឆ្នាំសិក្សា និងការបំប៉នសិស្សខ្សោយ បានធ្វើអោយអត្រាឡើងថ្នាក់សិស្សស្រីនៅថ្នាក់ទី៣-៩បានល្អជាបន្តបន្ទាប់។ យុទ្ធសាស្ត្រនេះនឹងត្រូវអនុវត្តបន្តទៀត ដើម្បីកាត់បន្ថយគំលាតយេនឌ័រនៃអត្រាពិតនៃការសិក្សា ព្រមទាំងកម្មវិធីអប់រំសាធារណៈនានា ដើម្បីធានាអោយបានថា កុមារីអាយុ ៦ ឆ្នាំ បានចូលរៀននៅបឋមសិក្សា។

ផែនការសកម្មភាពសំរាប់ការងារយេនឌ័របានទទួលស្គាល់ផងដែរ នូវការកែលំអអត្រាឆ្លងភូមិសិក្សាពីថ្នាក់ទី៦-៧ ជាបន្ទាន់ផងដែរ។ ថ្វីត្បិតតែអត្រាបោះបង់ការសិក្សានៅថ្នាក់ទី៦ បានកាត់បន្ថយពី ១៦% មកនៅ ១១.៤% កាលពី ៤ឆ្នាំ កន្លងមកនេះក៏ដោយ ក៏នេះនៅតែជាកត្តាដ៏សំខាន់មួយដែលត្រូវដោះស្រាយ អំពីបញ្ហាចំនួនសិស្សស្រីចូលរៀនបានតិចនៅ មធ្យមសិក្សា និងក្រោយមធ្យមសិក្សា។ កម្មវិធីអាហារូបករណ៍សំរាប់សិស្សក្រីក្រនៅថ្នាក់ទី៧-៩ នឹងត្រូវបែងចែក ៦០% សំរាប់សិស្សស្រី ដោយត្រូវជ្រើសរើសនាពេលបញ្ចប់ការសិក្សាថ្នាក់ទី៦។ ក្រសួងអប់រំ យុវជន និងកីឡា កំពុងរិះរក វិធានការថ្មីៗបន្ថែមទៀត ដើម្បីបង្កើនការចូលរៀនសិស្សស្រីនៅក្រោយថ្នាក់ទី៩ រួមមានការផ្តល់អាហារូបករណ៍ដល់ សិស្សក្រីក្រ និងសិស្សស្រីដែលរៀននៅថ្នាក់ទី១០-១២ និងសិក្សានៅថ្នាក់ក្រោយមធ្យមសិក្សា ព្រមទាំងការសាងសង់ អន្តេវាសិកដ្ឋានសំរាប់សិស្សស្រីនៅកំរិតឧត្តមសិក្សាផងដែរ។

យុទ្ធសាស្ត្រគន្លឹះមួយទៀតនោះគឺ ត្រូវបន្តពង្រីកកម្មវិធីផ្សេងៗរបស់ការងារអប់រំក្រៅប្រព័ន្ធ ដើម្បីអនុញ្ញាតអោយសិស្សបានចូលរៀនឡើងវិញនៅតាមភូមិសិក្សាផ្សេងៗ។ កម្មវិធីផ្សេងៗ បានផ្តល់ឱកាសដល់ស្ត្រីបានចូលរៀន ដោយបានបង្ហាញអោយឃើញថាមានសមាមាត្រខ្ពស់នៃការចូលរៀននៅក្នុងកម្មវិធីផ្សេងៗ ជាពិសេសកម្មវិធីអក្ខរកម្ម និងកម្មវិធីសមមូលនៅបឋមសិក្សា។ មធ្យោបាយផ្សេងទៀតនោះគឺ កម្មវិធីទាំងនេះនឹងផ្តល់ឱកាសជាលើកទី២ ដល់សិស្សបោះបង់ការសិក្សាអោយបានចូលរៀនឡើងវិញ និងបន្តទៅកំរិតបន្ទាប់ទៀត។ ក្រសួងអប់រំ យុវជន និងកីឡានឹងខិតខំប្រឹងប្រែង ដើម្បីធ្វើអោយកម្មវិធីទាំងនេះមានផលប៉ះពាល់ប្រកបដោយសុទិដ្ឋិ។ ជាដំបូង ត្រូវធានាស្តង់ដាអោយមានប្រសិទ្ធភាព និងការទទួលស្គាល់សញ្ញាប័ត្រ។ ទី២ ត្រូវដោះស្រាយបញ្ហាវិសាលភាពនៃការទទួលស្គាល់សញ្ញាប័ត្រជាផ្លូវការនៃកម្មវិធីអក្ខរកម្ម ដែលជាជំហានសំរាប់ឈានទៅបន្តការសិក្សាតទៅទៀត។ ទី៣ ត្រូវពិនិត្យមើលវិសាលភាពនៃការពង្រីកកម្មវិធីសមមូលនៅមធ្យមសិក្សា ដែលជាវិធានការរយៈពេលមធ្យមមួយ ដើម្បីជំរុញការចូលរៀនរបស់សិស្សស្រី។

*រូបភាពទី ១០ : គំលាតយេនឌ័រនៃបុគ្គលិកអប់រំ*




ក្រសួងអប់រំ យុវជន និងកីឡាយល់ឃើញថា ការបង្កើនចំនួនអ្នកគ្រប់គ្រង និងគ្រូបង្រៀនជានារីភេទ អាចធ្វើអោយមានផលប៉ះពាល់ជាវិជ្ជមានលើផ្នែកសមធម៌យេនឌ័រនៅគ្រប់កំរិតអប់រំ។ បច្ចុប្បន្ននេះ ដោយសារកត្តាកំរិតវប្បធម៌ គ្រូបង្រៀនជានារីមានប្រហែល៤0% នៃបុគ្គលិកបង្រៀននៅបឋមសិក្សា ប៉ុន្តែនៅមធ្យមសិក្សាទុតិយភូមិ អត្រានេះមានតែ ២២%។ សមាមាត្រនារីនៅក្នុងគ្រឹះស្ថានក្រោយមធ្យមសិក្សាមានចន្លោះពី ១0% ទៅ ៣0%។ នារីភេទមានចំនួន

តិចនៅក្នុងមុខតំណែងការងារគ្រប់គ្រង និងរដ្ឋបាល ជាពិសេសនៅតាមការិយាល័យស្រុក-ខ័ណ្ឌ (មុខតំណែងសំខាន់បំផុតសំរាប់ធ្វើវិមជ្ឈការ) ដែលមានត្រឹមតែ ១៦% នៃបុគ្គលិកសរុប តួលេខនេះឡើងឃើតដោយវាត្រូវចំណុះកត្តាមួយចំនួន។ ជាជំហានដំបូង គោលនយោបាយក្រសួងអប់រំ យុវជន និងកីឡា គឺត្រូវបង្កើនចំនួនបុគ្គលិកបង្រៀនជានារីភេទតាមមធ្យោបាយជាច្រើន។ តាមរយៈក្រុមការងារបញ្ជ្រាបយេនឌ័រ ក្រសួងនឹងធ្វើការពិនិត្យពិច្ច័យលើយុទ្ធសាស្ត្រនានាបន្ថែមទៀត ដើម្បីកែលំអឱកាសសំរាប់សិស្សនារី និងបុគ្គលិកជាស្ត្រីភេទនៅគ្រប់កំរិតទាំងអស់។

### ៦.២.២ ការរីកចំរើន និងផលប៉ះពាល់លើជនជាតិភាគតិច

ការកែលំអការទទួលសេវាអប់រំដែលមានគុណភាពខ្ពស់ប្រកបដោយសមធម៌ នៅតំបន់ជនជាតិភាគតិច នៅតែជាសមាសភាគដ៏សំខាន់មួយ នៃការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងកម្មវិធីគាំទ្រវិស័យអប់រំ។ ក្រសួងអប់រំ យុវជន និង កីឡាបានទទួលស្គាល់ថា យុទ្ធសាស្ត្រ និងកម្មវិធីរួមនៃ ESP/ESSP នឹងអាចដោះស្រាយបញ្ហាពាក់ព័ន្ធទាំងនេះបានខ្លះដែរ ជាមួយនឹងអន្តរាគមន៍ដែលយើងបានកំណត់។ យុទ្ធសាស្ត្រនេះមានផលប៉ះពាល់ជាវិជ្ជមានដល់កុមារនៅឃុំក្រីក្រ តំបន់ដាច់ស្រយាល និង ជនជាតិភាគតិច។ បន្ទាប់ពីបានអនុវត្តគំរូសាកល្បង ក្នុងខេត្ត-ក្រុងចំនួន៥ ដែលមានស្រុកចំនួន៦ ភូមិចំនួន១៧ ក្រុមចំនួន២៤ មាតាចំនួន៣៧២នាក់ កុមារសរុបចំនួន៥៦០នាក់ កុមារីចំនួន៣៨៣នាក់ ក្នុងនោះកុមារអាយុ៥ឆ្នាំមានចំនួន២៧២នាក់ស្មើនឹង៤៨% រួចមក កុមារមានការប្រែប្រួល ទាំងសុខភាព បញ្ញា ស្មារតី ទំនាក់ទំនងសង្គម និងជាពិសេសផ្នែកភាសា បង្កលក្ខណៈល្អដល់កុមារជនជាតិភាគតិចបានចូលរៀននៅសាលាបឋមសិក្សាតាមអាយុកំណត់។ ក្នុងតំបន់ជនជាតិភាគតិចដូចជា នៅខេត្តស្ទឹងត្រែងការចូលរៀននៅបឋមសិក្សាបានកើនឡើង ៦% និងនៅខេត្តរតនគីរីកើនឡើង១៦% ក្នុងឆ្នាំ២០០៣-០៤នេះ។ ក្នុងឆ្នាំសិក្សាកន្លងមក នៅខេត្តព្រះវិហារចំនួនសិស្សចុះឈ្មោះចូលរៀនសរុបនៅមធ្យមសិក្សាបឋមភូមិមានការកើនឡើង ២៧.៥% និងនៅខេត្តមណ្ឌលគីរី ៣៧%។ នៅមធ្យមសិក្សាបឋមភូមិការចូលរៀនរបស់សិស្សស្រីបានកើនលើស សិស្សប្រុស។

ទោះយ៉ាងណាក៏ដោយ អត្រារួមនៃការសិក្សា និងអត្រារួមចូលរៀនថ្មីនៅខេត្តទាំងនេះ មិនទាន់សំរេចបានតាមចំណុចដៅនៅឡើយទេ បើធៀបនឹងចំណុចដៅថ្នាក់ជាតិ (សូមមើលតារាង ៩)។ ឧទាហរណ៍ នៅខេត្តរតនគីរី អត្រាពិតនៃការសិក្សានៅបឋមសិក្សាមានត្រឹមតែ៥៤.៣%ប៉ុណ្ណោះ និងខេត្តមណ្ឌលគីរីមាន៧៤.៤% ក្នុងចំណោមខេត្តដែលមានអត្រាទាបជាងគេបំផុត។ នៅឆ្នាំសិក្សា២០០២-០៣ អត្រាពិតចូលរៀនថ្មីក៏មានកំរិតទាបផងដែរ អាស្រ័យដោយសិស្សចូលរៀនមិនតាមអាយុកំណត់ និងកំណត់តំរូវការនៃការសិក្សាមិនបានច្បាស់លាស់។ ដោយហេតុនេះហើយដែលតំរូវអោយដាក់ចេញនូវយុទ្ធសាស្ត្រជាក់លាក់នានា ដើម្បីដោះស្រាយការលំបាកក្នុងការចូលរៀននៅតំបន់ជនជាតិភាគតិច(ដូចជា កម្មវិធីអប់រំកុមារតូច កម្មវិធីសិក្សាពីរភាសា អាហារូបករណ៍ ការបណ្តុះបណ្តាលគ្រូជនជាតិភាគតិច និងកម្មវិធីផ្សេងៗទៀត)។

**តារាង ៩ : អាំងឌីកាទ័រសំខាន់ៗ សំរាប់ខេត្តជនជាតិភាគតិច ២០០៣-០៤ នៅបឋមសិក្សា**

| | អត្រាពិតចូលរៀនថ្មី | | | អត្រាពិតនៃការសិក្សា | | | | | |
|---|---|---|---|---|---|---|---|---|---|
| ខេត្ត | ស្រី | សរុប | គំលាត Gender | ស្រី | សរុប | គំលាត Gender | ផលធៀបសិស្ស-ថ្នាក់ ១-៦ | ផលធៀប សិស្ស-បន្ទប់ | ផលធៀប សិស្ស-គ្រូ |
| មណ្ឌលគីរី | 50.7% | 55.4% | 8.9 | 65.9% | 74.4% | 17.0 | 34 | 47 | 40 |
| ព្រះវិហារ | 66.5% | 66.3% | -0.4 | 81.9% | 82.6% | 1.4 | 38 | 59 | 41 |
| រតនគីរី | 35.5% | 40.1% | 9.0 | 46.4% | 54.3% | 15.2 | 36 | 46 | 52 |
| ស្ទឹងត្រែង | 75.1% | 77.7% | 5.1 | 85.6% | 88.4% | 5.9 | 33 | 51 | 36 |
| **ថ្នាក់ជាតិ** | *77.4%* | *78.7%* | *2.5* | *88.6%* | *90.1%* | *2.8* | *45* | *67* | *45* |

នៅតំបន់ជនជាតិភាគតិច ពុំទាន់មានសេវាអប់រំមធ្យមសិក្សាគ្រប់គ្រាន់នៅឡើយទេ។ អត្រាពិតនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តចំនួន ៤ នៅមានកំរិតទាប គឺក្រោម ១០% បើធៀបនឹងអត្រាថ្នាក់ជាតិមាន ២១%។ ដូចគ្នានេះដែរ នៅមធ្យមសិក្សាទុតិយភូមិ អត្រាពិតនៃការសិក្សាមានកំរិតទាបធៀបនឹងអត្រាជាមធ្យមថ្នាក់ជាតិ ៨%។ ទោះជាយ៉ាងនេះក្តី ការចុះឈ្មោះចូលរៀននៅមធ្យមសិក្សាក្នុងតំបន់ជនជាតិភាគតិចកំពុងកើនឡើងយ៉ាងលឿន ពីបន្ទាត់គោលទាបបំផុតនៃចំណុចដៅអប់រំ។ ក្នុងឆ្នាំសិក្សា២០០៣-០៤ ក្រសួងបានបន្តអនុវត្តវិធានការជាក់លាក់ចំនួនពីរ ដើម្បីដោះស្រាយបញ្ហានេះ តាមរយៈការផ្តល់សម្ភាររូបវ័ន្តសំរាប់សាលាមធ្យមសិក្សា និង ផ្តល់អាហារូបករណ៍ ឬការលើកទឹកចិត្តសំរាប់សិស្សជនជាតិភាគតិច។

ក្រសួងអប់រំ យុវជន និងកីឡា ក៏កំពុងរិះរកអន្តរាគមន៍បន្ថែមទៀត ដើម្បីកែលំអការអប់រំនៅតំបន់ជនជាតិភាគតិច ។ យុទ្ធសាស្ត្រមួយចំនួន នឹងប្រើប្រាស់បេទពិសោធន៍ដែលទទួលបានពីកម្មវិធីសាកល្បងលើការងារអក្ខរកម្ម ការអប់រំផ្អែកលើសហគមន៍ កម្មវិធីសិក្សាពីរភាសា និងការអភិវឌ្ឍបុគ្គលិក។ នៅឆ្នាំសិក្សា២០០៤-០៥ ក្រសួងមានបំណង ពង្រីងរាល់អន្តរាគមន៍ជាក់លាក់នៅតំបន់ជនជាតិភាគតិច ដូចជាវិធានការបណ្តុះបណ្តាលនិងវិក្រឹតការគ្រូបង្រៀននៅបឋមសិក្សា និងមធ្យមសិក្សា ព្រមទាំងពង្រីកកម្មវិធីសិក្សាពីរភាសានៅថ្នាក់ដំបូងនៃបឋមសិក្សា ។

បន្ថែមពីនេះទៀត ក្រសួងកំពុងដោះស្រាយបញ្ហាសាលារៀនមានមិនគ្រប់កំរិតថ្នាក់ជាច្រើននៅក្នុងខេត្តទាំងនេះ។ ក្នុងឆ្នាំសិក្សា២០០៣-០៤ សាលាបឋមសិក្សាមានមិនគ្រប់កំរិតថ្នាក់មានចំនួន ៣៣២ សាលា(ស្មើនឹង៧៤%) ក្នុងចំណោមសាលាមិនគ្រប់កំរិតសរុប៤៤៨សាលា។ ក្រសួងអប់រំ យុវជន និងកីឡាកំពុងពិចារណាលើយុទ្ធសាស្ត្រ ពង្រីកការលើកទឹកចិត្តអភិវឌ្ឍន៍ស្ថាប័នអោយដល់សាលារៀនទាំងអស់នេះ ស្របគ្នានឹងការដោះស្រាយឥទ្ធិពលវប្បធម៌របស់ខេត្តទាំងនេះ។ គោលដៅរួម គឺត្រូវអភិវឌ្ឍគ្រឹះស្ថានសិក្សាប្រកបដោយចីរភាព ដែលអាចផ្តល់សេវាអប់រំមានលក្ខណៈសមស្រប និងការចំណាយមានប្រសិទ្ធភាព ។

## ៦.៣ ការអប់រំនៅតំបន់ដាច់ស្រយាល និង តំបន់ព្រំដែន : ការរីកចំរើន និង ផលប៉ះពាល់

ក្រសួងអប់រំ យុវជន និង កីឡាបានធ្វើការវិភាគយុទ្ធសាស្ត្រលើបញ្ហាដែលពាក់ព័ន្ធដល់ការកែលំអសេវាអប់រំនៅតំបន់ដាច់ស្រយាល និងតំបន់ព្រំដែន ក៏ដូចជាបញ្ហាសាលារៀនខ្នាតតូច និងសាលារៀនមានមិនគ្រប់កំរិតថ្នាក់។ ក្រសួងអប់រំ យុវជន និងកីឡាកំពុងអនុវត្តវិធានការមួយចំនួន ដើម្បីកែលំអសេវាអប់រំនៅតំបន់ និងសាលារៀនជួបការលំបាក តាមរយៈគំនិតផ្តួចផ្តើមផ្សេងៗដូចជា ការបង្រៀនពីរវេន ការបង្រៀនថ្នាក់គួប និងការផ្តល់ប្រាក់លើកទឹកចិត្តគ្រូនៅតំបន់ដាច់ស្រយាល។ ប៉ុន្មានឆ្នាំកន្លងមកនេះ ក្រសួងបានធ្វើការពិនិត្យឡើងវិញ នូវវិសាលភាពក្នុងការអនុវត្តយុទ្ធសាស្ត្រលើកទឹកចិត្តសិស្ស និងគ្រូបង្រៀន។

ក្នុងឆ្នាំសិក្សា២០០២-០៣ ជាដំណាក់ការដំបូងនៃការអនុវត្តកម្មវិធីកែលំអប្រសិទ្ធភាពសេវាអប់រំ ដោយបានផ្តល់ប្រាក់លើកទឹកចិត្តដើម្បីពង្រាយបុគ្គលិកតាមការកំណត់ទុក។ ការផ្តល់ថវិកាសរុបនៅឆ្នាំដំបូងមានចំនួន ១០ពាន់លានរៀលស្មើនឹង (US$ 2.5 million)។ ក្នុងឆ្នាំ២០០៣ លក្ខណៈសំខាន់ៗនៃកម្មវិធីពង្រាយគ្រូឡើងវិញមានដូចជា ក) គ្រូចំនួន ១,៤៤៧ នាក់ត្រូវបានពង្រាយទៅកាន់កន្លែងការងារថ្មី នៅក្នុងនិងក្រៅឃុំ-សង្កាត់របស់ខ្លួន ខ) គ្រូចំនួន ១៥,២៨៦នាក់ បានទទួលប្រាក់ឧបត្ថម្ភសំរាប់បំពេញការងារនៅតំបន់ជួបការលំបាក និងតំបន់ដាច់ស្រយាល ដើម្បីធានាអោយការពង្រាយគ្រូមានសមធម៌ និងការរក្សាបុគ្គលិកដែលមានគុណភាពខ្ពស់ អោយនៅបំរើការទីនោះបានយូរអង្វែង ។ មេរៀនបទពិសោធន៍សំខាន់ៗមានសង្ខេបជូនដូចខាងក្រោម :

- ថ្វីបើឧបត្ថម្ភតែ១លើកលើការពង្រាយគ្រូឡើងវិញម្នាក់ អស់ទឹកប្រាក់ប្រមាណពី ៣០០,០០០រៀល ទៅ ១.៥លានរៀល (US$75–377) ប្រាក់នេះនៅមិនទាន់គ្រប់គ្រាន់សំរាប់ធានាដល់ការពង្រាយបុគ្គលិកឡើងវិញបានឡើយ ។ គេនៅមានការលំបាកផ្សេងៗទៀត ក្រោយពេលពង្រាយរួចហើយ។
- ជាមួយនឹងកម្មវិធីតាំងទីលំនៅថ្មី យើងនៅមានបញ្ហាមួយចំនួនចំពោះកំរិត និងប្រភេទនៃការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តដែលអាចជំរុញអោយបុគ្គលិកនិងគ្រួសាររបស់គេអាចតាំងទីលំនៅនៅតំបន់ថ្មីបាន ព្រោះថាពួកគេរស់នៅបែកពីគ្រួសារ បញ្ហារកដីផលិតស្បៀង បញ្ហារកប្រាក់ចំណូល និងពុំមានលទ្ធភាពរកលំនៅដ្ឋាននៅតំបន់ថ្មីបាន ។
- ការពង្រាយគ្រូចេញថ្មីអោយទៅបំរើការនៅសាលារៀនដែលខ្វះគ្រូក្នុងតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក អាចដំណើរការកាន់តែមានប្រសិទ្ធភាព និងចីរភាព ប្រសិនបើឧបសគ្គនៃការតាំងទីលំនៅថ្មីនេះត្រូវបានកាត់បន្ថយ ។

មេរៀនបទពិសោធន៍ទាំងនេះត្រូវបានពិនិត្យឡើងវិញ នៅក្នុងផ្នែកមួយនៃកំណែលំអយុទ្ធសាស្ត្រពង្រាយបុគ្គលិកឡើងវិញរបស់ក្រសួងអប់រំ យុវជន និងកីឡា សំរាប់ឆ្នាំ ២០០៤ តទៅ ។

សភាពធ្ងន់ធ្ងររបស់សាលារៀនមានមិនគ្រប់កំរិតថ្នាក់ នៅតាមឃុំ-សង្កាត់ជាប់ព្រំដែនអាចមានផលវិបាកច្រើន។ ទី១ បង្កើនអត្រាបោះបង់ការសិក្សានៅបឋមសិក្សា និងបង្កើនចំនួនយុវជននៅក្រៅសាលា។ ទី២ ធ្វើអោយអត្រាឆ្លងភូមិ

សិក្សាទៅមធ្យមសិក្សាបឋមភូមិថយចុះ និងកាត់បន្ថយចំនួនសិស្ស ដែលត្រូវការសំរាប់ការសិក្សានៅមធ្យមសិក្សា។ ការចូលរៀននៅមធ្យមសិក្សានៅតំបន់ជាប់ព្រំដែនកាន់តែថយចុះ ដោយសារលទ្ធភាពភាពផ្តល់សម្ភាររូបវន្តសំរាប់សាលាមធ្យមសិក្សាបឋមភូមិនិងទុតិយភូមិនៅមានកំរិត។ ស្រុកនៅជាប់ព្រំដែនចំនួន១២ ពុំមានសម្ភាររូបវន្តសាលាមធ្យមសិក្សាបឋមភូមិស្មើនឹង២០% នៃចំនួនសរុប បើធៀបនឹងស្រុកមិនជាប់ព្រំដែនមានតែ៨%។ ស្រុកនៅជាប់ព្រំដែន ដែលពុំមានសាលាមធ្យមសិក្សាទុតិយភូមិមានប្រមាណ ៤៧% ហើយ ស្រុកមិនជាប់ព្រំដែនមានប្រមាណ ២៥%។

ក្រសួងអប់រំ យុវជន និងកីឡាត្រូវមានការខិតខំដោយឡែកមួយទៀត ចំពោះការងារគ្រប់គ្រង និងការផ្តល់សេវាអប់រំនៅតំបន់ដាច់ស្រយាល និងតំបន់ព្រំដែន។ ជាជំហានដំបូង ត្រូវមានវិធានការកែលំអការគ្រប់គ្រងធនធានដែលមានស្រាប់ (ដូចជា ការធានាផ្តល់សៀវភៅសិក្សាអោយទាន់ពេលវេលា ការអភិវឌ្ឍគ្រូនៅនឹងកន្លែង) និង ពង្រឹងសហប្រតិបត្តិការរវាងស្រុក និងសាលារៀននៅដាច់ស្រយាល។ យុទ្ធសាស្ត្ររបស់ក្រសួងអប់រំ យុវជន និង កីឡា សំរាប់តំបន់ដាច់ស្រយាល និងតំបន់ព្រំដែន នឹងត្រូវអនុវត្តចាប់ពីឆ្នាំ២០០៤ តទៅ ហើយផ្តោតលើបញ្ហាដែលបានកំណត់ ។